

ការផ្ដល់ព័ត៌មានអំពីសិទ្ធិ

# សិទ្ធិរបស់ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

# សិទ្ធិ ស្របតាមច្បាប់ជួញដូរមនុស្ស



| | ① | ② | ③ | ④ | ⑤ | ⑥ |
|---|---|---|---|---|---|---|
| ប្រសិនបើអ្នកចង់ទទួលបានការការពារ | ទទួលបានការការពារពីទីភ្នាក់ងារនានា | ប្រាក់ចំណូលពីធ្វើការងារនៅក្នុងអំឡុងពេលនៃការការពារ | ចរិការប្រឆាំងការជួញដូរមនុស្ស | ប្រាក់ឈ្នួលសរុបពីនិយោជក | សំណងជាសាក្សីក្នុងរឿងក្តីព្រហ្មទណ្ឌ | សំណងពីជនល្មើស |
| | មណ្ឌលរបស់ រដ្ឋាភិបាលឬអង្គការក្រៅរដ្ឋាភិបាល | យ៉ាងហោចណាស់ទទួលបានប្រាក់កម្រៃអប្បរមា សម្រាប់អ្នកដែលចង់ធ្វើការងារក្រៅមណ្ឌល | ចំណាយលើការ រស់នៅ សុខភាព សំណង ចំណាយមាតុភូមិនិវត្ត ចរិកាសហប្រតិបត្តិ | ផ្អែកលើការចរចារជាមួយនឹងនិយោជក ដូចជាកម្រៃនិងការថែមម៉ោង | ករណីពាក់ព័ន្ធជាមួយនឹងបទល្មើសផ្លូវភេទ | តុលាការមានសិទ្ធិអំណាចក្នុងការបញ្ជារឱ្យជនល្មើសបង់សំណងឱ្យទៅជនរងគ្រោះ |
| ប្រសិនបើអ្នកមិនចង់ទទួលបានការការពារ* | | | ចរិការប្រឆាំងនឹងការជួញដូរមនុស្ស | ប្រាក់ឈ្នួលសរុបពីនិយោជក | សំណងជាសាក្សីក្នុងរឿងក្តីព្រហ្មទណ្ឌ | សំណងពីជនល្មើស |

*សម្គាល់: ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អាចត្រូវបានអញ្ជើញមកផ្តល់ពត៍មានបន្ថែម នៅពេលក្រោយ។ ចំណាយលើថ្លៃធ្វើដំណើរ ជាបន្ទុករបស់ទីភ្នាក់ងារដែលអញ្ជើញ ហើយត្រូវមានការការពារសុវត្ថិភាពដល់ជនរងគ្រោះនិងក្រុមគ្រួសាររបស់ពួកគេ។

ទទួលការការពារ
ពីទីភ្នាក់ងារ

# មណ្ឌលរដ្ឋាភិបាល

មណ្ឌលរដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាល




**ផ្នែកប្រឆាំងការជួញដូរមនុស្សទូរស័ព្ទ លេខ**
02202 9074 – 6

**មណ្ឌលគាំទ្រអ្នកមានវិបត្តិទូរស័ព្ទលេខ**
1300 ( 24 Hours)



## សេវាស្នាក់នៅ




ការណែនាំតម្រង់ទិស


អាហារ ៣ពេល ក្នុង ១ថ្ងៃ


ប្រឹក្សាយោបល់


បណ្តុះបណ្តាលវិជ្ជាជីវៈ


ត្រៀមរៀបចំសាក្សី


ការអប់រំ


ការងារ


សកម្មភាពកំសាន្ត


ការធ្វើសមាហរណកម្ម

# រយៈពេលមធ្យមនៅមណ្ឌល

- ពិនិត្យឯកសារ
- ផ្តល់ព័ត៌មានពីសិទ្ធិ

**0 – 3 ខែ**

- ស្នើសុំព័ត៌មាន
- ទទួលដំបូង
- ប្រឹក្សាយោបល់
- សេវាសុខភាព/ពិនិត្យរាងកាយ
- ស្តារផ្នែកផ្លូវកាយនិងផ្លូវចិត្ត
- ជំនួយផ្នែកច្បាប់
- ទាមទារសំណង
- បណ្តុះបណ្តាលវិជ្ជាជីវៈ
- រកការងារឱ្យធ្វើ

**3 – 6 ខែ**

- ការត្រៀមខ្លួនជាសាក្សីក្នុងនីតិវិធីច្បាប់
- ជំនាញបំណិតជីវិតមុនពេលមាតុភូមិនិវត្ត
- មាតុភូមិនិវត្តទៅគ្រួសារ/កន្លែងដើមវិញ

## ប្រាក់ចំណូលពីធ្វើការងារនៅក្នុងអំឡុងពេលនៃការការពារ

យ៉ាងហោចណាស់ទទួលបានប្រាក់កម្រៃអប្បរមាសម្រាប់អ្នកដែលចង់ធ្វើការងារក្រៅមណ្ឌល



*ផ្នែកទី៣៧ នៃច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស* (2008)

**ទទួលបានការការពារនៅក្នុងមណ្ឌល**

↓ មិនលើសពី១សប្តាហ៍

**ក្នុងករណីមិនមែនជាជនជាតិថៃ ត្រូវដាក់ពាក្យសុំស្នាក់បណ្តោះអាសន្នក្នុងប្រទេសថៃ**

↓ មិនលើសពី១សប្តាហ៍

**សម្របសម្រួលជាមួយនឹងនាយកដ្ឋានការងារដើម្បីរកការងារសមរម្យ**

↓ ក្នុងរយៈពេល ១៥ ថ្ងៃ

**ធ្វើកិច្ចព្រមព្រៀងជាមួយនឹងនិយោជកអំពីម៉ោងការងារនិងប្រាក់កម្រៃ**

**សម្គាល់:**

- ជនរងគ្រោះអាចធ្វើការងារនៅក្នុងមណ្ឌល
- ជនរងគ្រោះអាចត្រូវបានអនុញ្ញាតឱ្យធ្វើការងារនៅក្រៅមណ្ឌល ប៉ុន្តែអាចធ្វើបានតែនៅក្នុងខេត្តដែលមណ្ឌលស្ថិតនៅ

# ថវិការប្រឆាំងនឹងការជួញដូរមនុស្ស



- ចំណាយលើការរស់នៅ — ៣០០០ បាត ក្នុងម្នាក់ កម្រិតត្រឹម ៣ ដងក្នុង ១ ឆ្នាំ
- ចំណាយសុខភាព — ៣០០០ បាត ក្នុងម្នាក់ កម្រិតត្រឹម ៣ ដងក្នុង ១ ឆ្នាំ
- ចំណាយលើស្តារឡើងវិញ — កម្រិតត្រឹម ២០០០០បាត
- សំណងសម្រាប់អសមត្ថភាពធ្វើការងារ — ៣០០ បាត ក្នុង១ ថ្ងៃ កម្រិតត្រឹម ១ ឆ្នាំ
- ទំនិញបរិភោគ — ៣០០០ បាត ក្នុងម្នាក់ កម្រិតត្រឹម ៣ ដងក្នុង ១ ឆ្នាំ
- ថ្លៃស្នាក់នៅ
- ចំណាយការអប់រំ/បណ្តុះបណ្តាល
- ចំណាយនីតិវិធីច្បាប់/ការទាមទារសំណង
- ចំណាយធ្វើមាតុភូមិនិវត្តទៅកន្លែងដើមវិញ (រថយន្ត រថភ្លើង ។ល។)
- ចំណាយធ្វើមាតុភូមិនិវត្ត(សំបុត្រយន្តហោះ)

ផ្អែកលើការយល់ព្រមរបស់គណៈកម្មធិការថវិការប្រឆាំងការជួញដូរមនុស្ស តាមករណីនីមួយៗ

ផ្អែកប្រឆាំងការជួញដូរមនុស្ស ទូរស័ព្ទលេខ
0 2202 9024-5
0 2202 9031-2

## ប្រាក់កើនបាន មកពីនិយោជក

ចំនួនប្រាក់កម្រៃមិនត្រូវបានបើកឱ្យ ដែលជនរងគ្រោះមានសិទ្ធិទទួលបានពីនិយោជក



**ផ្អែកលើការចរចារជាមួយនឹងនិយោជក**

- ប្រាក់ឈ្នួល
- ប្រាក់ថែមម៉ោង
- ប្រាក់ថ្ងៃឈប់សម្រាក
- ប្រាក់ឈ្នួលថែមម៉ោងនៅថ្ងៃឈប់សម្រាក

## សំណងជាសាក្សីក្នុងរឿងក្ដីព្រហ្មទណ្ឌ

ជនរងគ្រោះក្នុងរឿងក្ដីព្រហ្មទណ្ឌពាក់ព័ន្ធនឹងបទល្មើសផ្លូវភេទ (យោងតាមច្បាប់ស្ដីពីការបង្ការនិងបង្ក្រាបអំពើបេស្យាចារ)



**នាយកដ្ឋានការពារសិទ្ធិនិងសេរីភាព បង់ប្រាក់មិនលើសពី ៣០០០០ បាត ទេ**

## សំណងពីជនល្មើស

តុលាការមានសិទ្ធិអំណាចក្នុងការកបញ្ជារជនល្មើសបង់សំណងឱ្យទៅជនរងគ្រោះ



*ផ្អែកទី៣៥ នៃច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស (2008)*

# សំណង*

## ❶ការខូចខាតទ្រព្យសម្បត្តិ

- ចំណាយការធ្វើដំណើរ
- កម្រៃជើងសារ
- តម្លៃទ្រព្យសម្បត្តិ ដែលជនល្មើសរឹបអូស ឬបំផ្លិចបំផ្លាញ
- ចំណាយលើការថែទាំសុខភាព (ជាក់ស្ដែង)
- ការបាត់បង់ចំណូល
- ការបាត់បង់ឱកាសការងារ

## ❷ការខូចខាតផ្សេងទៀត

- ការរំលោភលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស
- ការឈឺចាប់ផ្លូវកាយនិងផ្លូវចិត្ត
- ការបាត់បង់កេរ្តិ៍ឈ្មោះ
- ការខូចខាតសម្ថភាពខួរក្បាលនិងរាងកាយ
- ការបាត់បង់សុភមង្គលនិងសុខមាលភាព
- ការបាត់បង់សេរីភាព

**សំណងដែលជនរងគ្រោះម្នាក់ៗទទួលបានអាស្រ័យលើអង្គហេតុនៃករណី ភាពធ្ងន់ធ្ងរ រយៈពេលនិងផលប៉ះពាល់នៃអំពើ។*

**ចំនួនខ្ពស់បំផុតគឺ ៨០០ ០០០ បាត ទទួលបាបចាប់ពីថ្ងៃកាត់ឱ្យជាប់ទោស*

## ទម្រង់សម្រាប់ការផ្តល់ព័ត៌មានអំពីសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ធ្វើនៅ...................................................

ថ្ងៃ.................... ខែ.................... ឆ្នាំ....................

ខ្ញុំឈ្មោះ លោក/លោកស្រី/កញ្ញា ........................................ អាយុ ............... សញ្ជាតិ ....................

លេខកាត/លេខឯកសារសម្គាល់ខ្លួន.......................................

ការធ្វើមាតុភូមិនិវត្តន៍ដោយ ☐ ស្ម័គ្រចិត្ត ☐ ដោយបង្ខំ

☐ មន្ត្រីក្រសួងអភិវឌ្ឍន៍សង្គមនិងសន្តិសុខមនុស្ស បានប្រាប់ខ្ញុំអំពីសិទ្ធិស្របតាមច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ២០០៨ គឺខ្ញុំមានសិទ្ធិដូចតទៅនេះ៖

១. ប្រសិនបើខ្ញុំចង់ទទួលបានការការពារ ខ្ញុំមានសិទ្ធិទទួលបានជំនួយសមស្របសម្រាប់អាហារ ការស្នាក់នៅ ការថែទាំសុខភាព ការស្តារឡើងវិញផ្លូវកាយនិងផ្លូវចិត្ត ការអប់រំ ការបណ្តុះបណ្តាល ជំនួយផ្លូវច្បាប់ និងការវិលត្រឡប់មកផ្ទះវិញ ដោយសុវត្ថិភាពនិងសេចក្តីថ្លៃថ្នូរ។

២. សិទ្ធិស្នាក់នៅបណ្តោះអាសន្ននៅក្នុងប្រទេសថៃ ដោយអាចធ្វើការងារជាបណ្តោះអាសន្ន ដូចដែលមានចែងក្នុងច្បាប់។

៣. សិទ្ធិមានសុវត្ថិភាពនិងការការពារសម្រាប់ជនរងគ្រោះនិងក្រុមគ្រួសារ មុនពេល ក្នុងកំឡុងពេល និងក្រោយពេលផ្តន្ទាទោសជនល្មើស។ ជនរងគ្រោះដែលជាសាក្សីនៅក្នុងដំណើរការរឿងក្តីប្រឆាំងនឹងជនជួញដូរមនុស្ស ទទួលបានការការពារក្រោមច្បាប់ការពារសាក្សី ។

៤. សិទ្ធិទាមទារសំណង ការខូចខាត និងបដិទាន ខណៈដែលបន្តរឿងក្តីព្រហ្មទណ្ឌប្រឆាំងនឹងជនជួញដូរមនុស្ស។ ជំនួយនេះត្រូវផ្តល់ដល់ជនរងគ្រោះដោយមិនគិតកម្រៃ ដោយសារវាជាផ្នែកមួយនៃការផ្តល់សេវាដល់ជនរងគ្រោះ។

៥. សិទ្ធិរបស់ជនរងគ្រោះដែលមិនត្រូវរងការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋដូចតទៅនេះ៖ ការចូលទៅប្រទេសថៃដោយខុសច្បាប់ ដូចមានចែងនៅក្នុងច្បាប់អន្តោប្រវេសន៍ ការផ្តល់ព័ត៌មានមិនពិតនិងការចោទប្រកាន់ចំពោះមន្ត្រីសាធារណៈ ការប្រើប្រាស់ឯកសារសម្គាល់ខ្លួនឬឯកសារធ្វើដំណើរក្លែងក្លាយដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ បទល្មើសដូចដែលមានចែងក្នុងច្បាប់ស្តីពីការបង្ការនិងបង្ក្រាបបេស្យាចារ និងធ្វើការងារដោយមិនមានការអនុញ្ញាត ដូចដែលមានចែងនៅក្នុងច្បាប់ការងារសម្រាប់ជនបរទេស។ ប៉ុន្តែ មន្ត្រីតុលាការអាចផ្តន្ទាទោសជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលបានប្រព្រឹត្តិបទល្មើសខាងលើ ប្រសិនបើមានការអនុញ្ញាតជាលាយលក្ខអក្សររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

៦. សិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុពីថវិកាសម្រាប់ការងារប្រឆាំងការជួញដូរមនុស្ស។

ខ្ញុំទទួលស្គាល់និងយល់ពីសិទ្ធិជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

☐ ខ្ញុំមិនចង់ទទួលជំនួយដោយសារតែ .......................................................
អ្នកអាចទាក់ទងខ្ញុំតាម .......................................................

☐ ខ្ញុំស្ម័គ្រចិត្តទទួលយកការការពារ នៅឯ .......................................................
ហើយខ្ញុំនឹងអនុវត្តតាមបទបញ្ជាទាំងអស់ដែលបានកំនត់ដោយណ្ឌល។

| | |
|---|---|
| ......................................... | ......................................... |
| អ្នកទទួលជំនួយ | មន្ត្រី |
| ......................................... | ......................................... |
| សាក្សី | សាក្សី/អ្នកបកប្រែ |

ក្រសួងអភិវឌ្ឍន៍សង្គមនិងសន្តិសុខមនុស្ស